# វិសមភាពយេនឌ័រក្នុងវិស័យកសិកម្ម៖ អង្កេតគ្រួសារសមាជិកអង្គការកសិករក្នុងបួនខេត្ត[១]

អត្ថបទនេះបង្ហាញពី ការវិភាគបែបពណ៌នាលើលទ្ធផលអង្កេតគ្រួសារកសិករ អនុវត្តដោយវិទ្យាស្ថាន CDRI នៅឆ្នាំ២០១១ ដែលជាផ្នែកមួយនៃការសិក្សា ដើម្បីពិនិត្យពីអត្ថប្រយោជន៍ និងឧបសគ្គនៃការចូលរួមក្នុងអង្គការកសិករ (FO) សម្រាប់គ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ។ យោងតាមលទ្ធផលអង្កេត គ្រួសារមានស្ត្រីជាមេគ្រួ តំណាងឲ្យប្រហែល ២៦% នៃគ្រួសារទាំងអស់ដែលធ្វើកសិកម្ម ក្នុងតំបន់សិក្សា (CDRI ចេញផ្សាយក្នុងពេលឆាប់ៗ)[២] ។ ដូច្នេះ ការសិក្សាមានជាប់ទាក់ទងដោយផ្ទាល់ទៅនឹងគ្រួសារទាំងនេះ ព្រមទាំងបញ្ហាប្រឈមទូទៅដែល កសិករជាស្ត្រីត្រូវជួបប្រទះ។ ការសិក្សាផ្តោតទៅលើផលិតកម្មស្រូវ ដែលជាសកម្មភាពចម្បងគេក្នុងវិស័យកសិកម្ម និងជាអាទិភាពគោលនយោបាយរបស់រដ្ឋាភិបាល ហើយក៏ពិនិត្យផងដែរពីការចិញ្ចឹមសត្វ ដោយសារវាជាសកម្មភាពទូទៅមួយនៃអង្គការកសិករនៅកម្ពុជា។

## សាវតា និងហេតុផលនៃការសិក្សា

កំណើនសេដ្ឋកិច្ចនៅកម្ពុជា មានមូលដ្ឋានតូចចង្អៀត ដោយពឹងផ្អែកលើសសរស្តម្ភ ៤ រួមមាន វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម។ ទោះបីកម្ពុជាមានការផ្លាស់ប្តូររចនាសម្ព័ន្ធគួរឲ្យកត់សម្គាល់ចេញពីសេដ្ឋកិច្ចផ្អែកលើ កសិកម្មបែបចិញ្ចឹមពោះក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជានៅបន្តពឹងផ្អែកខ្លាំងលើវិស័យកសិកម្មដែលរួមចំណែកជាងមួយភាគបី (ប្រមាណ ៣៤% នៅឆ្នាំ២០១០) នៃ ផសស (NIS 2011)។ ទោះបីវិស័យកសិកម្មមានអត្រាកំណើនមធ្យមទាបជាងវិស័យឧស្សាហកម្ម និងសេវាកម្មក្តី ប៉ុន្តែវានៅតែមានលក្ខណៈធន់ល្អទៅនឹងផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលនៅឆ្នាំ២០០៩ ដោយបានដើរតួជាសំណាញ់សុវត្ថិភាពសង្គមដ៏សំខាន់ និងជាពោងសុវត្ថិភាពសេដ្ឋកិច្ច ហើយជួយសង្គ្រោះប្រជាជនមិនឲ្យយ៉ាប់យ៉ឺនខ្លាំងពេក ព្រមទាំងទប់ស្កាត់ ផសស មិនឲ្យមានកំណើនអវិជ្ជមាន។

វិស័យកសិកម្ម មានសក្តានុពលខ្លាំងដើម្បីក្លាយជាក្បាលម៉ាស៊ីនជំរុញកំណើន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចនៅកម្ពុជា ដោយបានផ្តល់ការងារដល់ប្រមាណ ៤៩,៥% នៃកម្លាំងពលកម្មសរុបនៅឆ្នាំ២០១១ (NIS 2012)។ វិស័យនេះមានលក្ខណៈសម្គាល់ចម្បងមួយគឺ គ្រួសារនៅជនបទមានកម្មសិទ្ធិលើក្បាលដីតូចៗ៖ ដោយឡែកនៅឆ្នាំ២០០៩ ៤៦,៩% នៃគ្រួសារទាំងអស់ មានដីកសិកម្មតិចជាងមួយហិកតា។ ម្យ៉ាងទៀត ទិន្នន័យបានពីជំរឿនឆ្នាំ២០០៨ បង្ហាញថា ៦៦,១% នៃស្ត្រីមានការងារធ្វើ (អាយុពី ១៥ ទៅ ៦៤ឆ្នាំ) បានចូលរួមធ្វើកសិកម្មបែបចិញ្ចឹមពោះ ធៀបនឹងប្រហែល ៦០% នៃបុរសដែលមានការងារធ្វើ (NIS 2009)[៣]។ ដូច្នេះការអភិវឌ្ឍវិស័យកសិកម្ម ជាមធ្យោបាយមានឥទ្ធិពលធំទូលាយ និងប្រសិទ្ធភាពខ្ពស់ ក្នុងការលើកកម្ពស់កម្រិតជីវភាពនៅតាមជនបទ ជាពិសេសសម្រាប់ស្ត្រី។

ដើម្បីសម្រេចចក្ខុវិស័យថ្នាក់ជាតិនៃ ការអភិវឌ្ឍវិស័យកសិកម្ម រដ្ឋាភិបាលបានទទួលស្គាល់ និងផ្តល់អាទិភាពលើការជំរុញកសិកម្មរបស់ម្ចាស់ដីតូចៗ និងការបង្កើតអង្គការកសិករដោយកំណត់វាជាគន្លឹះនៃ យុទ្ធសាស្ត្រក្នុងការលើកកម្ពស់ជីវភាព ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ជនបទ និងការកាត់បន្ថយភាពក្រីក្រ (Chea 2010)។ អង្គការកសិករ រំពឹងថាអាចជួយពួកសមាជិកឲ្យមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានព័ត៌មានធាតុចូល និងបច្ចេកទេសផ្សេងៗ ដែលជួយលើកកម្ពស់ផលិតភាពកសិកម្មរបស់កសិករមានដីធ្លីតូចៗ និងបង្កើតលទ្ធភាពរួមគ្នាក្នុងការចូលទៅកាន់ទីផ្សារធាតុចូល និងផលិតផលកសិកម្មដើម្បីឲ្យផលិតករខ្នាតតូច នៅតាមជនបទអាចទាញយកគុណប្រយោជន៍ពីសេដ្ឋកិច្ចមាត្រដ្ឋាន។

## ការពិនិត្យគ្រួសៗពីអង្គការកសិករនៅកម្ពុជា

ទាំងក្នុងគោលគំនិត និងការអនុវត្តជាក់ស្តែង អង្គការកសិករក្នុងលក្ខណៈជាមធ្យោបាយដើម្បីសម្រេចបានការអភិវឌ្ឍកសិកម្មសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រនៅកម្រិតមូលដ្ឋានបានកើតមានជាយូរមកហើយ និងមានច្រើនបែបយ៉ាងនៅកម្ពុជា។ Couturier *et al.* (2006) រាយការណ៍ថា មានប្រហែល ១៣.០១៧ អង្គការកសិករ បានកកើតឡើងគិតត្រឹមឆ្នាំ២០០៥ ក្នុងនេះមានជាង ៦០% បានកកើតឡើងតាំងពីឆ្នាំ២០០០។ អង្គការកសិករនៅកម្ពុជាភាគច្រើន មានសមាជិកតិចជាង ៣០នាក់ ហើយមានតែ ១២% ប៉ុណ្ណោះដែលមានសមាជិកលើសពី ១០០នាក់។

អង្គការកសិករ ត្រូវបានបង្កើតឡើងដើម្បីជំរុញការអភិវឌ្ឍជនបទ តាមរយៈការកសាងសមត្ថភាពនិងសកម្មភាពរួមគ្នាដោយផ្អែកលើគោលការណ៍នៃការស្ម័គ្រចិត្ត ការជួយខ្លួនឯង ការពឹងលើខ្លួនឯង ប្រជាធិបតេយ្យ សមភាព សមធម៌ សាមគ្គីភាព និងការពង្រឹងសិទ្ធិអំណាច (Nou 2006)។ អង្គការកសិករភាគច្រើននៅកម្ពុជា ត្រូវបានអង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នរដ្ឋាភិបាលបង្កើតឡើង និងផ្តល់ជំនួយហិរញ្ញវត្ថុ និង/ឬ បច្ចេកទេសឲ្យ ដោយមានតួនាទីចម្បងជួយលើកកម្ពស់ លទ្ធភាពទទួលបានឥណទានតាមរយៈគម្រោងប្រាក់សន្សំជាក្រុម អាជីវកម្មជាក្រុម ការកសាងសមត្ថភាពផ្នែកបច្ចេកទេសកសិកម្ម និងការអភិវឌ្ឍសហគមន៍ (Couturier *et al.* 2006)។

ដំបូងឡើយ អង្គការកសិករមួយចំនួនធ្វើការតែជាមួយកសិករក្រីក្រខ្លាំងប៉ុណ្ណោះ ប៉ុន្តែវិធីសាស្ត្រនេះ មិនបានទទួលជោគជ័យទេ

---

[១] រៀបរៀងដោយ កែវ សុជាតិ អ្នកស្រាវជ្រាវ កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅវិទ្យាស្ថាន CDRI។

[២] តាមពិតអត្ថប្រយោជន៍ និងឧបសគ្គនៃអង្គការកសិករ សម្រាប់ស្ត្រីដែលរស់នៅក្នុងគ្រួសារមានបុរសជាមេគ្រួក៏គួរពិនិត្យផងដែរប៉ុន្តែប្លង់អង្កេតដែលប្រើប្រាស់ក្នុងករណីសិក្សានេះ មិនអនុញ្ញាតឲ្យធ្វើការវិភាគបែបនេះទេ។

[៣] ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យទទួលបានពីជំរឿនថ្នាក់ជាតិឆ្នាំ២០០៨។

តារាង ១៖ ប្រាក់កម្ចីជាមធ្យមរបស់សមាជិកអង្គការកសិករ បែងចែកតាមភេទរបស់មេគ្រួសារ

| | គ្រួសារសរុប | មេគ្រួសារជាស្ត្រី | មេគ្រួសារជាបុរស | t-test |
|---|---|---|---|---|
| ចំនួនគ្រួសារ | 330 | 83 | 247 | - |
| ប្រាក់កម្ចីជាមធ្យម | 306,000 | 208,000 | 339,000 | -1.4040 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកទៅលើទិន្នន័យអង្កេតរបស់ CDRI (ចេញផ្សាយនាពេលឆាប់ៗ)។ សម្គាល់៖ ដោយសារសមាជិកនៃអង្គការកសិករត្រូវផ្លាស់វេនគ្នាទទួលប្រាក់កម្ចី ហេតុនេះគ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ មិនមែនទទួលបានប្រាក់កម្ចីដំណាលគ្នារហូតនោះទេ។ ១ដុល្លារ=៤០០០រៀល។

ដោយសារកសិករទាំងនោះខ្វះខាតទ្រព្យផលិតកម្ម ទុន អក្ខរកម្ម និងជំនាញគ្រប់គ្រងចាំបាច់នានា ដើម្បីអនុវត្តតាមការណែនាំរបស់អង្គការកសិករ។ អ្នកមកពីខាងក្រៅ មានជាអាទិ៍ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬទីភ្នាក់ងារផ្ដល់ជំនួយដទៃទៀត ជាអ្នកផ្ដួចផ្ដើមបង្កើតអង្គការកសិករភាគច្រើន ហើយក្នុងគំរូតាង គ្មានអង្គការកសិករណាមួយបានកកើតឡើងដោយខ្លួនឯងទេ ប៉ុន្តែមានជាង ៦០% ប្រាប់ថា ទីភ្នាក់ងារផ្ដល់ជំនួយផ្សេងៗបានបង្កើតពួកគេឡើង។ គោលបំណងរបស់អង្គការកសិករប្រែប្រួលខុសគ្នាទៅតាម របៀបវារៈខុសៗគ្នារបស់ទីភ្នាក់ងារផ្ដល់ជំនួយ ប៉ុន្តែការផ្ដល់ប្រាក់សន្សំក្រៅផ្លូវការ និងគម្រោងឥណទានឆ្លាស់វេនគ្នា គឺជាទិសដៅរួម។

## ទិន្នន័យ និងវិធីសាស្ត្រស្រាវជ្រាវ

អង្កេតគ្រួសារបានធ្វើឡើងនៅឆ្នាំ២០១១ ក្នុងបួនខេត្ត គឺមាន បាត់ដំបង កំពង់ធំ កំពត និងស្វាយរៀង។ គំរូតាងនៃអង្កេត រួមមាន ៦៩៩គ្រួសារ ក្នុងនោះ ៣៣០គ្រួសារជាសមាជិកអង្គការកសិករ និង ៣៦៩គ្រួសារទៀត មិនមែនជាសមាជិកអង្គការកសិករទេ។ លើសពីនេះទៀតព័ត៌មានបែបគុណវិស័យ បានប្រមូលយកតាមការធ្វើសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះ និងការពិភាក្សាតាមក្រុមស្នូល ដើម្បីផ្ទៀងផ្ទាត់នឹងការវិភាគបែបពណ៌នាលើលទ្ធផលបានពីអង្កេត។ អ្នកស្រាវជ្រាវបានប្រៀបធៀបគុណប្រយោជន៍ និងគុណវិបត្តិនៃសមាជិកភាពក្នុងអង្គការកសិករ សម្រាប់គ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ។ ទោះបីជាមិនអាចសិក្សាពីសមាជិកគ្រួសារជាស្ត្រី និងជាបុរសម្នាក់ៗក្ដី ក៏ការសិក្សាពីផលប៉ះពាល់នៃសមាជិកភាពនៅក្នុងអង្គការកសិករ សម្រាប់គ្រួសារមានស្ត្រីជាមេគ្រួសារ អាចជួយកំណត់ពីចន្លោះខ្វះខាតក្នុងការបង្កើតបរិយាកាសអំណោយផល សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ ការពង្រឹងសិទ្ធិអំណាច និងការចូលរួមដ៏មានន័យរបស់ស្ត្រី។

## អត្ថប្រយោជន៍នៃការចូលជាសមាជិកអង្គការកសិករ

ជាទូទៅ សមាជិកអង្គការកសិករទទួលបានផលប្រយោជន៍ពីការសន្សំប្រាក់ជាក្រុម ការបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្ម និងការងារជាក្រុម។ ទិន្នន័យអង្កេតបង្ហាញថា សកម្មភាពចម្បងៗប្រាំរបស់អង្គការកសិករ សម្រាប់ទាំងគ្រួសារមានបុរសជាមេគ្រួ និងមានស្ត្រីជាមេគ្រួ គឺគម្រោងឥណទាននិងការសន្សំប្រាក់ បច្ចេកទេសចិញ្ចឹមសត្វ ការជួញដូរជី បច្ចេកទេសដាំដំណាំនិងដាំបន្លែ និងផលិតកម្មគ្រាប់ពូជ។ គ្រួសារទាំងពីរប្រភេទ មិនមានការយល់ឃើញខុសប្លែកគ្នាគួរឲ្យកត់សម្គាល់ទេចំពោះអង្គការកសិករ ទាំងក្នុងការជឿទុកចិត្ត ការពេញចិត្តនឹងផលប្រយោជន៍ និងការងារជាក្រុម។

### លទ្ធភាពទទួលបានឥណទាន

ពួកសមាជិកប្រើប្រាស់ឥណទានទទួលបានពី អង្គការកសិករដើម្បីធ្វើវិនិយោគក្នុងការងារកសិកម្មជាសំខាន់។ នៅតាមតំបន់ជនបទ កសិករមានដីតូចៗកំពុងបង្កើតជាក្រុមជួយខ្លួនឯងបានកាន់តែច្រើនឡើង ដោយក្នុងនោះសមាជិកនានាចូលរួមចំណែកក្នុងការសន្សំប្រាក់ ដើម្បីបង្កើតជាមូលនិធិសហគមន៍មួយដែលអាចឲ្យពួកគេខ្ចីប្រាក់បាន[៤]។ ឥណទាននៅក្នុងក្រុមជួយខ្លួនឯងច្រើនផ្ដល់ទៅឲ្យសមាជិកក្រុម សម្រាប់ធ្វើវិនិយោគក្នុងការងារកសិកម្មតែប៉ុណ្ណោះ មានទាំងការទិញធាតុចូលល្អៗ ដូចជា ចំណីសត្វ ជី គ្រាប់ពូជ ជាដើម។ ប៉ុន្តែក្រុមខ្លះអាចមានលទ្ធភាពបង្កើតសេវាឥណទាន សម្រាប់បំពេញតម្រូវការបន្ទាន់របស់សមាជិកក្រុមផងដែរ។ ការដាក់ពាក្យសុំខ្ចីប្រាក់ មានលក្ខខណ្ឌបែបបទសាមញ្ញ ប្រើពេលវេលា និងលិខិតស្នាមតិច ហើយអត្រាការប្រាក់មានកម្រិតទាប បើធៀបនឹងការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

> *យើងអាចទទួលបានកម្ចីយ៉ាងលឿននៅពេលកូនឈឺ។ តួយ៉ាង មានម្ដងនោះខ្ញុំគ្មានលុយសម្រាប់ចុះឈ្មោះកូនឲ្យចូលរៀនទេ។ ខ្ញុំបានព្យាយាមខ្ចីពីអ្នកផ្សេង (ប៉ុន្តែ) គេមិនឲ្យខ្ញុំខ្ចីសោះ។ ខ្ញុំបានស្នើទៅក្រុម ហើយសមាជិកក្រុមបានសម្រេចឲ្យខ្ញុំខ្ចីលុយខ្លះ ព្រោះពួកគេយល់ពីស្ថានភាពខ្ញុំ។ (សមាជិកស្ត្រីម្នាក់នៃអង្គការកសិករ នៅខេត្តបាត់ដំបង)*

ប្រាក់កម្ចីជាមធ្យមដែលអង្គការកសិករផ្ដល់ឲ្យសមាជិក មានប្រហែល ៣០៦.០០០រៀល (តារាង ១)។ ទឹកប្រាក់នេះតិចខ្លាំងណាស់សម្រាប់ឲ្យ កសិករពង្រីកផលិតកម្មកសិកម្មរបស់ខ្លួន។ ទឹកប្រាក់អប្បបរមាដែលអាចជួយបង្កើនផលិតភាព និងប្រាក់ចំណូលពីការដាំដុះ ឲ្យបានច្រើនគួរសម មិនមានកត់ត្រានៅក្នុងអង្កេតទេ ប៉ុន្តែកសិករមួយចំនួនបានឲ្យដឹងក្នុងពេលសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះថា ពួកគាត់ត្រូវការប្រហែល ២ លានរៀល។ ទោះយ៉ាងនេះក្ដី កសិករក្រីក្រនានានៅតែយល់ថាប្រាក់កម្ចីរបស់អង្គការកសិករមានប្រយោជន៍ចំពោះគាត់ ព្រោះ

[៤] ក្រុមជួយខ្លួនឯង ជាប្រភេទសម្បូរជាងគេនៃអង្គការកសិករនៅកម្ពុជា ហើយជាទូទៅមានសមាជិកតិចជាង ៣០នាក់។ ប្រភេទធំៗ២ទៀត គឺមាន សមាគមកសិករ (សមាជិកលើសពី ៣០នាក់) និងសហករណ៍កសិកម្ម (សមាជិកលើសពី ៣០នាក់ និងបានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។ ដោយសារភាពកំហិតផ្នែកពេលវេលា និងធនធាន ការសិក្សានេះប្រើពាក្យអង្គការកសិករ ជាពាក្យរួម តំណាងឲ្យអង្គការទាំងបីប្រភេទនេះ។

តារាង ២៖ ការបណ្តុះបណ្តាលពីផលិតកម្មកសិកម្ម ទទួលបានដោយគ្រួសារជាសមាជិកអង្គការកសិករ

| សេវាបណ្តុះបណ្តាល/ការណែនាំ | ចំនួនគ្រួសារ | សរុប (% គ្រួសារ) | គ្រួសារស្ត្រីជាមេគ្រួ (% គ្រួសារស្ត្រីជាមេគ្រួ) | គ្រួសារបុរសជាមេគ្រួ (% គ្រួសារបុរសជាមេគ្រួ) |
|---|---|---|---|---|
| ស្រូវ/បន្លែ | | | | |
| - ការគ្រប់គ្រងសត្វចង្រៃ និងជំងឺ | 221 | 66.97 | 60.24 | 69.23 |
| - បច្ចេកទេសដាំដំណាំ | 243 | 73.64 | 63.86 | 76.92 |
| - ពូជល្អៗ និងការជ្រើសគ្រាប់ពូជ | 236 | 71.52 | 68.67 | 72.47 |
| - ការប្រើជីគីមី | 186 | 56.36 | 49.40 | 58.70 |
| - ការធ្វើជីកំប៉ុសនិងការគ្រប់គ្រងកាកសំណល់សរីរាង្គ | 234 | 70.91 | 72.79 | 70.45 |
| - ការស្រោចស្រព និងការគ្រប់គ្រងទឹក | 176 | 53.33 | 43.37 | 56.68 |
| បច្ចេកទេសចិញ្ចឹមសត្វ | | | | |
| - ការកែលំអពូជសត្វ | 212 | 64.24 | 56.63 | 66.80 |
| - ការធ្វើជម្រុកសត្វ | 232 | 70.3 | 66.27 | 71.66 |
| - ការគ្រប់គ្រងជំងឺ | 215 | 65.15 | 59.04 | 67.21 |
| - ចំណីសត្វ និងការបំប៉ន | 207 | 62.73 | 60.24 | 63.56 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យអង្កេតរបស់ CDRI ឆ្នាំ២០១១

លក្ខខណ្ឌខ្ចីប្រាក់មិនសូវតឹងតែង។ អង្គការកសិករមួយចំនួនថែមទាំងផ្តល់កម្ចីមិនយកការប្រាក់ទៀតផង សម្រាប់រយៈពេលខ្លីៗ (សងវិញក្នុងរយៈពេលមួយខែ ឬឆាប់ជាងនេះ)។

គ្រួសារមានស្ត្រីជាមេគ្រួ ទទួលបានប្រាក់កម្ចីជាមធ្យម ២០៨.០០០រៀល ដែលស្មើនឹង ៦១% នៃប្រាក់កម្ចីផ្តល់ទៅឲ្យគ្រួសារមានបុរសជាមេគ្រួ ហើយទឹកប្រាក់នេះ នៅតិចខ្លាំងណាស់ បើធៀបនឹងទឹកប្រាក់ដែលត្រូវការ សម្រាប់ពង្រីកផលិតកម្មកសិកម្ម។ ម្យ៉ាងទៀត មានគ្រួសារមានស្ត្រីជាមេគ្រួ (៣៥%) តិចជាង គ្រួសារមានបុរសជាមេគ្រួ (៤១%) ដែលបានខ្ចីប្រាក់សម្រាប់ធ្វើវិនិយោគក្នុងផលិតកម្មផលដំណាំ និងមានគ្រួសារមានស្ត្រីជាមេគ្រួ ច្រើនជាង គ្រួសារមានបុរសជាមេគ្រួ ដែលប្រើប្រាក់កម្ចីបានពីអង្គការកសិករក្នុងគោលដៅផ្សេងទៀត ក្រៅពីការងារកសិកម្ម។

## ***សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងផលិតកម្មកសិកម្ម***

ទោះបីជាសមាជិកអង្គការកសិករ មិនអាចយល់បានទាំងអស់នូវការណែនាំបង្ហាត់បង្ហាញរបស់មន្ត្រីផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់ពួកគេក្តី ក៏ពួកគេទទួលបានចំណេះដឹងអនុវត្តជាក់ស្តែងលើបច្ចេកទេសកសិកម្មមួយចំនួន ដូចជា របៀបធ្វើជីកំប៉ុស និងប្រើជីលាមកសត្វ ការដាំដំណាំសម្រាប់ធ្វើជីធម្មជាតិ របៀបដាំបន្លែ និងការចិញ្ចឹមមាន់ ទា ជ្រូក។ ការពិភាក្សាតាមក្រុមស្នូល ក៏បានបង្ហាញដែរថា សមាជិកអង្គការកសិករមួយចំនួនទទួលបានសេវាបណ្តុះបណ្តាលពីទីភ្នាក់ងារផ្តល់ជំនួយ ខណៈដែលសមាជិកផ្សេងទៀតទទួលបានជំនួយពីទីភ្នាក់ងារផ្តល់ជំនួយផង[៥] និងពីមន្ទីរកសិកម្មខេត្តផង។

> *មន្ទីរកសិកម្មខេត្ត ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មទៅឲ្យសមាជិកអង្គការកសិករ យ៉ាងហោចណាស់បីខែម្តង។ (មន្ត្រីផ្នែកផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ខេត្តស្វាយរៀង)*

កម្មវិធីបណ្តុះបណ្តាលដែល សមាជិកអង្គការកសិករតែងទទួលបានញឹកញាប់បំផុត រួមមាន បច្ចេកទេសដាំដំណាំ ពូជដំណាំល្អៗ ផលិតកម្មគ្រាប់ពូជ ការធ្វើជីកំប៉ុស និងការគ្រប់គ្រងកាកសំណល់សរីរាង្គ ព្រមទាំងការធ្វើជម្រុកសម្រាប់សត្វចិញ្ចឹមនិងមាន់ទា។ មានស្ត្រីភាគតិចជាងបុរសដែលទទួលបានអត្ថប្រយោជន៍ផ្ទាល់ពីការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម លើកលែងតែការណែនាំអំពីការធ្វើជីកំប៉ុស និងការគ្រប់គ្រងកាកសំណល់សរីរាង្គ (តារាង ២)។

ភាពខុសគ្នានៃ លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម រវាងគ្រួសារមានបុរសជាមេគ្រួសារ និងគ្រួសារមានស្ត្រីជាមេគ្រួសារ (ទោះបីមិនសូវមានសារៈសំខាន់ខាងស្ថិតិក្តី) អាចជាលទ្ធផលនៃការរើសអើងដោយអចេតនារបស់ មន្ត្រីផ្តល់សេវា ចំពោះគ្រួសារមានស្ត្រីជាមេគ្រួ។ ម្យ៉ាងទៀត គ្រួសារមានស្ត្រីជាមេគ្រួ ទទួលបានទិន្នផលដំណាំ និងប្រាក់ចំណូលពីការចិញ្ចឹមសត្វ តិចជាង គ្រួសារមានបុរសជាមេគ្រួដែលមានដីកសិកម្មធំជាងផងដែរ (តារាង ៣)។

មន្ត្រីផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មខេត្ត បានរាយការណ៍ថា ហេតុផលមួយដែលធ្វើឲ្យគ្រួសារមានស្ត្រីជាមេគ្រួ ចូលរួមក្នុងការបណ្តុះបណ្តាលពីការធ្វើជីកំប៉ុស និងការគ្រប់គ្រងកាកសំណល់សរីរាង្គ ច្រើនជាង ក្នុងវគ្គបណ្តុះបណ្តាលផ្សេងទៀត គឺស្ត្រីមិនមានពេលគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងគ្រប់សកម្មភាពរបស់អង្គការកសិករនោះទេ ហើយម្យ៉ាងទៀតបច្ចេកទេសសាមញ្ញទាំងនេះ វាជាប់ទាក់ទងនឹងការងារផ្ទះប្រចាំថ្ងៃផង។

[៥] ទីភ្នាក់ងារផ្តល់ជំនួយទាំងនោះ ជាអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសទៅឲ្យអង្គការកសិករ។ អង្គការកសិករខ្លះទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬពីមន្ទីរកសិកម្មខេត្ត ហើយខ្លះទៀតទទួលជំនួយពីអង្គភាពទាំងពីរនេះ ជាពិសេស សហករណ៍កសិកម្ម ព្រោះមន្ទីរកសិកម្មខេត្តមានទំនួលខុសត្រូវជួយដល់ពួកគេ។

តារាង ៣៖ ផលិតកម្មស្រូវ និងសត្វចិញ្ចឹម នៃគ្រួសារជាសមាជិកអង្គការកសិករ

| | ទាំងពីរប្រភេទ | ស្ត្រី | បុរស | t-test |
|---|---|---|---|---|
| ដីដាំស្រូវ(ហិកតា) | 1.60 | 1.10 | 1.80 | -3.04 |
| ទិន្នផលស្រូវក្នុងមួយឆ្នាំ (គីឡូក្រាម/ហិកតា) | 1958 | 1783 | 2015 | -1.57 |
| ចំណូលពីដំណាំស្រូវក្នុងមួយឆ្នាំ (ម៉ឺនរៀល/ហិកតា) | 206.170 | 169 | 219 | -2.22 |
| ចំណាយលើធាតុចូលសម្រាប់ដំណាំស្រូវ*ក្នុងមួយឆ្នាំ (ម៉ឺនរៀល/ហិកតា) | 62 | 61.77 | 61.19 | -0.018 |
| ចំណេញដុលពីដំណាំស្រូវក្នុងមួយឆ្នាំ (ម៉ឺនរៀល/ហិកតា) | 162.53 | 124.85 | 174.93 | -1.89 |
| ចំណូលពីសត្វចិញ្ចឹមក្នុងមួយឆ្នាំ (ម៉ឺនរៀល) | 465.12 | 336.37 | 506.35 | -1.85 |
| ចំណាយលើសត្វចិញ្ចឹមក្នុងមួយឆ្នាំ (ម៉ឺនរៀល) | 75.23 | 34.44 | 88.19 | -0.93 |
| ចំណូលសុទ្ធពីសត្វចិញ្ចឹមក្នុងមួយឆ្នាំ**(ម៉ឺនរៀល) | 389.89 | 301.92 | 417.85 | -1.89 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យអង្កេតរបស់ CDRI (ឆ្នាំ២០១១)

សម្គាល់៖ ១ ដុល្លារ = ៤០០០រៀល; *មិនរួមបញ្ចូលថ្លៃពលកម្ម; **ចំណូលសុទ្ធ = ចំណូល - ចំណាយលើធាតុចូល

ចំណូលពីដំណាំស្រូវរបស់គ្រួសារមានស្ត្រីជាមេគ្រួ វាទាបជាង ចំណូលពីដំណាំស្រូវរបស់គ្រួសារមានបុរសជាមេគ្រួ (ក្នុងកម្រិតសារៈសំខាន់ផ្នែកស្ថិតិ ៥%) បើទោះជាគ្រួសារទាំងពីរក្រុមទទួលបានទិន្នផលស្រូវប្រហាក់ប្រហែលគ្នាក្ដី (តារាង ៣)។ ហេតុផលមួយក្នុងនោះ អាចមកពីផ្ទៃដីដាំស្រូវជាមធ្យមរបស់គ្រួសារមានបុរសជាមេគ្រួសារ វាធំជាង ផ្ទៃដីដាំស្រូវរបស់គ្រួសារមានស្ត្រីជាមេគ្រួ។ បើគិតពីប្រាក់ចំណេញដុលផង[៦] ផលិតកម្មស្រូវរបស់គ្រួសារមានស្ត្រីជាមេគ្រួ មានប្រសិទ្ធភាពតិចជាង ផលិតកម្មស្រូវរបស់គ្រួសារមានបុរសជាមេគ្រួ (ក្នុងកម្រិតសារៈសំខាន់ផ្នែកស្ថិតិ ១០%)។ ចំណុចនេះបង្ហាញថា គ្រួសារមានស្ត្រីជាមេគ្រួសារអាចបង្កើនផលិតកម្មកសិកម្មបាន ប្រសិនបើពួកគេចេះប្រើប្រាស់កាន់តែប្រសើរនូវសេវាផ្នែកផលិតកម្មកសិកម្ម និងមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានប្រាក់កម្ចីសម្រាប់កែលំអការដាំដុះរបស់ខ្លួន។ ទាក់ទងនឹងផលិតកម្មសត្វចិញ្ចឹមវិញ គ្រួសារមានស្ត្រីជាមេគ្រួសារ ទទួលបានប្រាក់ចំណូលសុទ្ធពីការចិញ្ចឹមសត្វ តិចជាខ្លាំង បើធៀបនឹង គ្រួសារមានបុរសជាមេគ្រួ ទោះបីភាពខុសគ្នានេះមិនសូវមានសារៈសំខាន់ផ្នែកស្ថិតិក្ដី។

## បញ្ហាប្រឈមចំពោះអង្គការកសិករ

អង្កេតគ្រួសារ បង្ហាញពី កត្តាមួយចំនួនដែលរាំងស្ទះប្រសិទ្ធភាពរបស់អង្គការកសិករ ក្នុងលក្ខណៈជាយន្តការសម្រាប់លើកកម្ពស់ផលិតភាព និងផ្សារភ្ជាប់កសិករតូចតាចទៅនឹងទីផ្សារ (តារាង ៤)។ កត្តារាំងស្ទះទី១ គឺកង្វះទុន ដែលជាប់ទាក់ទងផ្ទាល់ទៅនឹងចីរភាពនៃអង្គការកសិករ។ មុខងារបឋមរបស់អង្គការកសិករនៅកម្ពុជា គឺពង្រីកការផ្ដល់ឥណទានដែលប្រហែលត្រូវពឹងផ្អែកលើហិរញ្ញប្បទានពី អង្គការមិនមែនរដ្ឋាភិបាល ឬទីភ្នាក់ងាររដ្ឋាភិបាល (Nou 2006)។ មានគ្រួសារមានបុរសជាមេគ្រួ (៨៥,៤៣%) ច្រើនជាង គ្រួសារមានស្ត្រីជាមេគ្រួសារ (៧៤,៧%) ដែលយល់ឃើញថា កង្វះឥណទានជាបញ្ហាប្រឈមមួយ។

បញ្ហាទី២ សម្រាប់សមាជិកអង្គការកសិករ គឺដីកសិកម្មមានទំហំតូចពេក។ ស្ត្រីមានមតិបែបនេះច្រើនជាងបុរសបន្តិច ដោយហេតុថា ដីកសិកម្មរបស់គ្រួសារមានស្ត្រីជាមេគ្រួ មានទំហំតូចជាង ដីកសិកម្មរបស់គ្រួសារមានបុរសជាមេគ្រួ។ ដើម្បីប្រើបច្ចេកទេសកសិកម្ម ដែលខ្លួនបានរៀនពីទីភ្នាក់ងារផ្ដល់ជំនួយ គ្រួសារជាសមាជិកអង្គការកសិករ ត្រូវមានដីកសិកម្ម។ ជាក់ស្ដែងមានអង្គការកសិករខ្លះបានកំណត់ថា សមាជិកត្រូវតែមានដីកសិកម្មរបស់ខ្លួនផ្ទាល់។ គួរកត់សម្គាល់ថា សន្តិសុខដីធ្លី និងការចុះបញ្ជីដីធ្លី ជាបញ្ហាចោទយូរមកហើយនៅកម្ពុជា ហើយកម្មសិទ្ធិដីស្របច្បាប់ ផលិតភាពកសិកម្មក៏ជាប់ទាក់ទងគ្នាដែរ ព្រោះកម្មសិទ្ធិដីមានសុវត្ថិភាព ជំរុញគ្រួសារនានាឲ្យធ្វើវិនិយោគលើកសិកម្ម (Tong 2011)។

អនក្ខរភាពរបស់សមាជិកអង្គការ គឺជាបញ្ហាប្រឈមមួយទៀត ជាពិសេសសម្រាប់គ្រួសារមានស្ត្រីជាមេគ្រួ។ អង្កេត បង្ហាញថា ៤៩,៤០% នៃមេគ្រួសារជាស្ត្រី និង ៨០% នៃមេគ្រួសារជាបុរសចេះអាននិងចេះសរសេរ។ មេគ្រួសារជាស្ត្រីមានការអប់រំជាមធ្យមប្រហែលបីឆ្នាំ រីឯមេគ្រួសារជាបុរស មានការអប់រំជាមធ្យមប្រហែលប្រាំឆ្នាំ។ គ្រួសារទាំងពីរប្រភេទយល់ឃើញស្រដៀងគ្នាថាអនក្ខរភាពជាបញ្ហាចោទមួយមែន។

ទោះបីសមាជិកអង្គការកសិករអាចទទួលបានព័ត៌មាន និងការបណ្ដុះបណ្ដាលអំពី ផលិតកម្មកសិកម្មផ្ដល់ដោយទីភ្នាក់ងារផ្ដល់ជំនួយក្ដី ក៏មានជាង ៥០% នៃសមាជិកអង្គការកសិករក្នុងអង្កេតបានប្រាប់ថា ព័ត៌មាននិងការបណ្ដុះបណ្ដាលទាំងនោះមិនសូវមានប្រយោជន៍ទេ។ ស្ត្រី និងបុរស ហាក់យល់ឃើញខុសគ្នាខ្លះក្នុងបញ្ហានេះ ដោយសារមានការងារកសិកម្មខុសគ្នា ប៉ុន្តែអង្កេតរបស់យើងមិនបានពិនិត្យពីកត្តានេះទេ។ ហេតុផលមួយដែលអាចនាំឲ្យសមាជិកអង្គការកសិករ ចាត់ទុកបញ្ហានេះថាសំខាន់ គឺប្រហែលមកពី អង្គការកសិករទាំងឡាយដែលមានការពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាលនោះ ត្រូវតែបង្ហាញថា ខ្លួនបានបំពេញតាមរបៀបវារៈរបស់ម្ចាស់ជំនួយហើយ (Couturier *et al.* 2006)។

បញ្ហាប្រឈមសំខាន់បំផុតមួយចំពោះអង្គការកសិករ គឺលទ្ធភាពចូលទៅកាន់ទីផ្សារ ដែលជួយឲ្យផលិតករខ្នាតតូចនៅ

[៦] ចំណេញដុល = (ចំណូល - ចំណាយលើធាតុចូល)/ផ្ទៃដីដាំស្រូវ។

តារាង ៤៖ ការយល់ឃើញពីឧបសគ្គចំពោះអង្គការកសិករ (គិតជា %)

| | គ្រួសារទាំងអស់ | គ្រួសារស្ត្រីជាមេគ្រួ | គ្រួសារបុរសជាមេគ្រួ |
|---|---|---|---|
| កង្វះឥណទាន | 82.73 | 74.7 | 85.43 |
| កង្វះដីកសិកម្ម* | 79.7 | 81.93 | 78.95 |
| អនក្ខរភាព | 79.39 | 80.72 | 78.95 |
| កង្វះការគាំទ្រពីខាងក្រៅ(ការទទួលបានព័ត៌មាននិងសេវាកម្ម) | 70.61 | 65.06 | 72.47 |
| ចំណេះដឹងនិងបច្ចេកទេសពិបាកអនុវត្ត ផ្តល់ដោយទីភ្នាក់ងារផ្តល់ជំនួយ | 68.79 | 71.08 | 68.02 |
| ចំណេះដឹងតិចតួចអំពីការធ្វើផែនការ | 63.94 | 61.45 | 64.78 |
| អង្គការកសិករមិនឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិក | 62.12 | 61.45 | 62.35 |
| ការអនុវត្តមិនត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង | 61.21 | 56.63 | 62.75 |
| កង្វះអ្នកដឹកនាំល្អ | 51.82 | 48.19 | 53.04 |
| រចនាសម្ព័ន្ធក្រុមមិនល្អ | 50.3 | 49.4 | 50.61 |
| កង្វះទឹកចិត្តចូលរួមក្នុងសកម្មភាពរួម | 45.15 | 43.37 | 45.75 |
| ការច្រណែនគ្នាក្នុងចំណោមសមាជិក | 38.79 | 43.37 | 37.25 |
| ការចុះបញ្ជីគណនេយ្យនិងការគ្រប់គ្រងហិរញ្ញវត្ថុមិនបានល្អ | 36.36 | 37.35 | 36.03 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យអង្កេតរបស់ CDRI (ចេញផ្សាយនាពេលឆាប់ៗ)
សម្គាល់៖ *គ្រួសារមួយចំនួនលំបាកនឹងប្រើបច្ចេកទេសដែលគេបង្រៀន ដោយសារគាត់មានដីកសិកម្មតូចពេក។

ជនបទ អាចទទួលបានអត្ថប្រយោជន៍ពីសេដ្ឋកិច្ចមាត្រដ្ឋាន។ ប្រហែល ៨០% នៃគ្រួសារជាសមាជិកអង្គការកសិករ (ទាំងគ្រួសារមានបុរសនិងគ្រួសារមានស្ត្រីជាមេគ្រួ) មិនមានលទ្ធភាពរួមគ្នាក្នុងការទិញធាតុចូល និងលក់ផលិតផលនៅលើទីផ្សារឡើយ ហើយលទ្ធភាពរួមគ្នានេះជាសេវាដ៏សំខាន់ដែលគេរំពឹងថាអង្គការកសិករត្រូវផ្តល់ឲ្យបាន។ ការពិភាក្សាតាមក្រុមស្នូល និងការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ បានបង្ហាញថា បញ្ហាទំនុកចិត្តមិនមានចោទទេ។ ពួកកសិករបញ្ជាក់ថា ការចូលទៅទីផ្សារជារួម ឬជាបុគ្គល គ្មានអ្វីខុសគ្នាច្រើនទេ ប៉ុន្តែជួនកាលការសម្របសម្រួលការចូលទៅទីផ្សារជារួម វាលំបាកជាងការចូលទៅជាលក្ខណៈបុគ្គល។ បញ្ហានេះជានិន្នាការមួយគួរឲ្យបារម្ភ ហើយអាចនាំឲ្យពួកសមាជិកមានការរិះគន់ថា អង្គការកសិករខ្វះការគាំទ្រពីខាងក្រៅ ខ្វះលទ្ធភាពទទួលបានព័ត៌មាន និងមានការបារម្ភថា រចនាសម្ព័ន្ធក្រុមមានលក្ខណៈអន់ខ្សោយ (តារាង ៤)។

## អនុសាសន៍គោលនយោបាយមួយចំនួន សម្រាប់លើកកម្ពស់ការងារសមភាពយេនឌ័រក្នុងកសិកម្ម

ទោះបីជាអង្គការកសិករមួយចំនួន បានបង្កើតយុទ្ធសាស្ត្ររបស់ខ្លួនផ្ទាល់សម្រាប់ផ្តល់ឥណទាន ទាំងនៅក្នុង និងតាមរយៈអង្គភាពរបស់ខ្លួនក្តី ក៏រដ្ឋាភិបាលត្រូវបង្កើតឲ្យមានគោលនយោបាយ និងសេវាកម្មផ្តល់ឥណទានជាក់លាក់ផ្សេងៗ ដើម្បីធានាថាគ្រួសារមានបុរសនិងមានស្ត្រីជាមេគ្រួមានលទ្ធភាពដូចគ្នា ដើម្បីទទួលបានឥណទាន។

ការបណ្តុះបណ្តាលអំពីផលិតកម្មកសិកម្ម ជាធាតុចូលដ៏ចាំបាច់សម្រាប់ញ៉ាំងឲ្យអង្គការកសិករមានប្រសិទ្ធភាព ហើយវាសំខាន់ខ្លាំងពេកមិនអាចទុកឲ្យអង្គការកសិករ និងរបៀបវារៈរបស់ទីភ្នាក់ងារផ្តល់ជំនួយនានា គ្រប់គ្រងតែឯងបានទេ។ រដ្ឋាភិបាល ត្រូវមានយុទ្ធសាស្ត្របណ្តុះបណ្តាលដ៏សក្តិសិទ្ធិមួយ ដែលជួយឲ្យអង្គការកសិករ អាចពង្រឹងសេវាកម្មផ្សេងៗផ្តល់ទៅឲ្យសមាជិកខ្លួន។ ការបណ្តុះបណ្តាលទាំងនេះ គួរមានដាក់បញ្ចូលនូវ ព័ត៌មាន និងជំនួយបច្ចេកទេស ទាក់ទងនឹងការធ្វើផែនការ ការផ្សព្វផ្សាយក្នុងទីផ្សារ និងលទ្ធភាពទិញលក់ផលិតផលនៅក្នុងទីផ្សារ។ ម៉្យាងទៀត គួរមានការបណ្តុះបណ្តាលជាក់ស្តែងលើគ្រប់មុខព្រួញនៃផលិតកម្មកសិកម្ម ហើយកម្មវិធីទាំងឡាយគួរបំពេញឲ្យបានតាមតម្រូវការជាក់ស្តែងរបស់ស្ត្រី ទាំងក្នុងខ្លឹមសារ និងការអនុវត្ត។ ការគិតគូរទៅដល់យេនឌ័រ គួររួមមាន កម្រិតអក្ខរភាពរបស់ស្ត្រី ការរៀបចំការបណ្តុះបណ្តាលឲ្យបានស្របតាមទំនួលខុសត្រូវនៅក្នុងគ្រួសារ ដូចជា ពេលម៉ោងដែលស្ត្រីអាចចូលរួមបាន និងរបៀបរៀបចំជួយមើលថែទាំកុមារ។ ស្ត្រី ទំនងត្រូវការនូវការកសាងសមត្ថភាព ដែលជួយលើកទឹកចិត្តពួកគេឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗ ដើម្បីទទួលបានជំនាញមូលដ្ឋានផ្នែកអាជីវកម្ម និងការចរចា។

ដើម្បីឲ្យខ្លួនកាន់តែមានអត្ថប្រយោជន៍ទ្វេឡើងទៀត អង្គការកសិករត្រូវលើកកម្ពស់លទ្ធភាពរួមគ្នាក្នុងការទិញធាតុចូល និងលក់ផលិតផលនៅលើទីផ្សារ។ ម៉្យាងទៀត ត្រូវមានការទទួលស្គាល់ និងគាំទ្រតួនាទីរបស់ស្ត្រីនៅក្នុងផលិតកម្មកសិកម្ម និងត្រូវមានការផ្តល់សិទ្ធិអំណាចដល់ទាំងគ្រួសារមានស្ត្រី និងមានបុរសជាមេគ្រួ ឲ្យចូលរួមដោយស្មើភាពគ្នាក្នុងសកម្មភាពនេះ។ ការធ្វើបែបនេះ អាចជួយជំរុញឲ្យមានការផ្លាស់ប្តូរឈានទៅកាន់កសិកម្មបែបពាណិជ្ជកម្មខ្នាតតូច និងជួយស្ត្រីនៅតាមជនបទឲ្យចេញផុតពីការធ្វើកសិកម្មចិញ្ចឹមពោះ។

## ឯកសារយោង

តទៅទំព័រ ២៧

សន្យាលើការផ្តល់សេវាសុខាភិបាល។ បន្ទាប់ពីគម្រោងដំណើរការបានពាក់កណ្តាលពេលកំណត់ ក្រុមស្រាវជ្រាវធ្វើការបូកសរុបលទ្ធផលការងារសម្រេចបានមកទល់បច្ចុប្បន្ន និងត្រៀមរៀបចំអនុវត្តដំណាក់កាលបន្ទាប់ទៀត។ គម្រោងស្រាវជ្រាវរយៈពេលពីរឆ្នាំ ស្តីពី "ការសិក្សាពីពលកម្មកុមារ" ចែកចេញជា បួនអនុគម្រោង ក្នុងនោះមានពីរបានចាប់អនុវត្តក្នុងខែមករា គឺមាន "ការងារក្នុងផ្ទះ របស់កុមារ" និង "ផលប៉ះពាល់លើពលកម្មកុមារនៃចំណាកស្រុកមនុស្សពេញវ័យ"។ ការសិក្សានេះជាផ្នែកមួយនៃ គម្រោងរយៈពេល ៤ឆ្នាំ មានឈ្មោះថា "Cambodians-EXCEL" របស់អង្គការទស្សនៈពិភពលោកកម្ពុជា ដែលទទួលបានហិរញ្ញប្បទានពី ក្រសួងការងាររបស់សហរដ្ឋអាមេរិក។ ឯកសារគោលគំនិតសម្រាប់អនុគម្រោង "ភាពជាដៃគូរវាងវិស័យឯកជននិងរដ្ឋ ដើម្បីផ្តល់ការអប់រំបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ (TVET)" ដែលទ្រទ្រង់ដោយ Sida បានចងក្រងចប់សព្វគ្រប់ ហើយក្រុមស្រាវជ្រាវកំពុងធ្វើការសិក្សាលើឯកសារយោង។ បច្ចុប្បន្នក្រុមស្រាវជ្រាវក្នុងកម្មវិធីSDកំពុងអនុវត្តគម្រោងពីរគឺ"ការត្រួតពិនិត្យពីលទ្ធផលផ្នែកអនាម័យនៅកម្ពុជា" និង "ការវាយតម្លៃផលប៉ះពាល់នៃគម្រោងផ្តល់មូលនិធិដោយ CARF"។ មានសំណើស្រាវជ្រាវជាច្រើនត្រូវបានរៀបចំ និងដាក់ស្នើឡើង ហើយក្នុងនោះមាន សំណើមួយសម្រាប់គម្រោង ReBUILD និងសំណើផ្សេងៗទៀតសម្រាប់ការស្រាវជ្រាវអំពី ទំនួលខុសត្រូវផ្នែកសង្គមកិច្ចរបស់ក្រុមហ៊ុនចិន និងអាហារូបត្ថម្ភកុមារ។

*តពីទំព័រ ១៧* **ទិសមភាពយេនឌ័រ...**


CDRI–Cambodia Development Resource Institute (forthcoming), *Impact Assessment of Farmer Organisation on Food Security of the Rural Poor,* CDRI Working Paper (Phnom Penh: CDRI)

Chea Saint Dona (2010), *Final Report on Policy Analysis for Farmer Organisation Development, Department of Agricultural Extension* (Phnom Penh: MAFF, sponsored by IFAD and FAO)

Couturier Julie, Savun Sam Ol& Ham Phalla (2006), "Inventory of Farmer Organisations in Cambodia, Cambodia", report prepared for Department of Agricultural Extension, Phnom Penh

NIS–National Institute of Statistics (2011), *National Accounts of Cambodia 1993-2011* (Phnom Penh: Ministry of Planning)

NIS–National Institute of Statistics (2009), *Population Census of Cambodia 2008* (Phnom Penh: Ministry of Planning)

NIS–National Institute of Statistics (2012), *Cambodia Socio-Economic Survey 2011* (Phnom Penh: Ministry of Planning)

Nou Keosothea (2006), "Emerging Structure of Agricultural Cooperatives in Cambodia", *Cambodia Development Review,* Vol.10 (1) (Phnom Penh: CDRI) pp.9-12

Tong Kimsun (2011), "Land Tenure and Paddy Productivity: Evidence from Rural Cambodia", *Annual Development Review 2010-2011* (Phnom Penh: CDRI) pp.143-155



## Cambodia Development Review—2013 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒ Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.